**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ...៧០...ស.សរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការចម្រុះអន្តរក្រសួង ដើម្បីស្រាវជ្រាវករណីផ្ទុះអាវុធពេលអនុវត្តសេចក្តីសម្រេចរបស់តុលាការ នៅភូមិក្បាលស្ពាន ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ :** បង្កើតគណៈកម្មការចម្រុះអន្តរក្រសួង ដើម្បីស្រាវជ្រាវករណីផ្ទុះអាវុធពេលអនុវត្តសេចក្តីសម្រេចរបស់តុលាការ បង្កឱ្យមានស្លាប់ និងរបួសដល់ប្រជាពលរដ្ឋ នៅភូមិក្បាលស្ពាន ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ដែលមានសមាសភាពដូចខាងក្រោម :

១- ឯកឧត្តម **ឯម សំអាន** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ ជាប្រធាន

២- ឯកឧត្តម **ហ៊ុន តៀង** រដ្ឋលេខាធិការ ក្រសួងការពារជាតិ ជាអនុប្រធាន

៣- ឯកឧត្តម **ខ្ទូត លុច** រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ ជាអនុប្រធាន

៤- ឯកឧត្តមនាយឧត្តមសេនីយ៍ **ហុក ឡុងឌី** អគ្គស្នងការនគរបាលជាតិ ជាសមាជិក

៥- ឯកឧត្តមឧត្តមសេនីយ៍ឯក **សៅ សុខា** មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស ជាសមាជិក

៦- ឯកឧត្តម **ភុល ទីរក្ស** អគ្គាធិការរង ក្រសួងមហាផ្ទៃ ជាសមាជិក

៧- ឯកឧត្តមអភិបាលខេត្តបន្ទាយមានជ័យ ជាសមាជិក

**ប្រការ២ :** គណៈកម្មការចម្រុះអន្តរក្រសួងមានភារកិច្ច :

- ស្រាវជ្រាវ ស៊ើបអង្កេតរកឱ្យឃើញកងកំលាំងប្រដាប់អាវុធ ឬមន្ត្រីរាជការណា ដែលជាអ្នកដៃដល់ និងជាអ្នកសមគំនិតក្នុងហេតុការណ៍ផ្ទុះអាវុធបណ្តាលឱ្យប្រជាពលរដ្ឋស្លាប់ចំនួន ០៥ នាក់ និងរបួសចំនួន ០៧ នាក់ ក្នុងពេលដែល កំលាំងចំរុះចុះអនុវត្តដីកាសម្រេចរបស់តុលាការ នៅភូមិក្បាលស្ពាន ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ កាលពីថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៥
- ចាត់វិធានការ និងដាក់វិន័យរដ្ឋបាលចំពោះជនដៃដល់ និងអ្នកសមគំនិតទាំងអស់ រួចហើយកសាង និងបញ្ជូនសំណុំរឿងទៅតុលាការ ដើម្បីចាត់ការតាមច្បាប់ជាធរមាន
- រាយការណ៍អំពីលទ្ធផលដែលសម្រេចបាន តាមជំហាននីមួយៗជូនប្រមុខរាជរដ្ឋាភិបាល ។

**ប្រការ៣ :** អនុប្រធាន និង សមាជិកគណៈកម្មការចម្រុះអន្តរក្រសួងត្រូវចូលរួមប្រជុំ និងចូលរួមបំពេញភារកិច្ចតាមការអញ្ជើញ និងការណែនាំរបស់ប្រធាន ។

**ប្រការ៤ :** គណៈកម្មការចម្រុះអន្តរក្រសួងនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ ។ ក្នុងករណីចាំបាច់ គណៈកម្មការចំរុះអន្តរក្រសួងអាចបង្កើតអនុគណៈកម្មការ ឬក្រុមការងារជំនាញ ដើម្បីជួយក្នុងកិច្ចការស្រាវជ្រាវនេះ ។

**ប្រការ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គស្នងការនគរបាលជាតិ ប្រធានស្ថាប័ន អង្គភាពពាក់ព័ន្ធទាំងអស់ និងឯកឧត្តមដែលមានឈ្មោះក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ [illegible] ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ